ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៤៤៥ ប្រក. សហវ / កសក

[illegible]

# ប្រកាសរួម

## ស្តីពី

## សោហ៊ុយសេវាកម្មត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

### រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យ លេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋាន

ផែនការ និង ស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និង មជ្ឈមណ្ឌលព័ត៌មាន និង ឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៣ ស្តីពីការត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១ :** រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបានស្នើសុំធ្វើការត្រួតពិនិត្យអនាម័យសត្វ ឬ ផលិតផលមានដើមកំណើតពីសត្វ លើទំនិញរបស់ខ្លួន ត្រូវបង់សោហ៊ុយសេវាកម្មត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ។

**ប្រការ ២ :** សោហ៊ុយសេវាកម្មត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ ត្រូវកំណត់បែងចែកដូចខាងក្រោម ÷

- សោហ៊ុយសេវាកម្មសម្រាប់ធ្វើចរាចរក្នុងផ្ទៃប្រទេស
- សោហ៊ុយសេវាកម្មសម្រាប់ធ្វើចរាចរនាំចេញ នាំចូល
- សោហ៊ុយសេវាកម្មសម្រាប់ធ្វើចរាចរឆ្លងកាត់ប្រទេស ។

សោហ៊ុយសេវាកម្មត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ ត្រូវបានកំណត់នៅក្នុងតារាងឧបសម្ព័ន្ធភ្ជាប់ប្រកាសនេះ ។ តារាង ឧបសម្ព័ន្ធនេះមានការកែប្រែក្នុងករណីចាំបាច់។

សោហ៊ុយសេវាកម្មនេះ មិនរាប់បញ្ចូលសោហ៊ុយវិភាគនៅមន្ទីរពិសោធន៍ទេ។

**ប្រការ ៣ :** ការធ្វើចរាចរឆ្លងកាត់ប្រទេស ក្នុងករណីគ្រោះថ្នាក់ដោយចៃដន្យក្នុងពេលដឹកជញ្ជូនបណ្តាលឱ្យមានការបាក់បែក ឬ របើកសម្ភារៈវេចខ្ចប់ទំនិញ ឬ គ្រោះថ្នាក់ដល់សត្វ ម្ចាស់ទំនិញត្រូវរាយការណ៍ជាបន្ទាន់ដល់សមត្ថកិច្ចត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ អាជ្ញាធរមានសមត្ថកិច្ចដែលនៅជិតបំផុតដើម្បីធ្វើការត្រួតពិនិត្យ។ សមត្ថកិច្ចត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ ត្រូវអនុវត្តវិធានបសុពេទ្យជាបន្ទាន់ រួចផ្តល់វិញ្ញាបនបត្រត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វជាថ្មី សម្រាប់បន្តនាំចេញ ហើយម្ចាស់ទំនិញត្រូវបង់សោហ៊ុយសេវាកម្មត្រួតពិនិត្យអនាម័យតាមកំរិតកំណត់ក្នុងតារាងសម្រាប់ធ្វើចរាចរនាំចេញ នាំចូលនៃប្រកាសនេះ។

**ប្រការ ៤ :** សោហ៊ុយសេវាកម្មត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ ត្រូវបង់ចូលថវិកាជាតិ។

**ប្រការ ៥** : មុខទំនិញ និង ការិតសោហ៊ុយសេវាកម្មត្រួតពិនិត្យអនាម័យសត្វ និង ផលិតផលមានដើមកំណើតពីសត្វ អាចបំពេញបន្ថែម និង មានការកែប្រែ បើមានការចាំបាច់ ។

**ប្រការ ៦** : ប្រកាស ឬ សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៧** : អគ្គនាយកនៃក្រសួង និង អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង អង្គភាពក្រោមឱវាទ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលពាក់ព័ន្ធត្រូវអនុវត្តប្រកាសរួមនេះតាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ២០០៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៩ ខែ១០ ឆ្នាំ ២០០៨

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ** **រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

**គាត ឈន់** **ចាន់ សារុន**

**__កន្លែងទទួល:__**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត-ក្រុង
- ដូចប្រការ ៧
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ - ភ្ជាប់ប្រកាស លេខ......៤៤៥......ប្រក.កសក ចុះថ្ងៃទី...០៩... ខែ...តុលា...ឆ្នាំ ២០០៨

-ភ្ជាប់ប្រកាស លេខ......៥៥៤......សហវ.ប្រក ចុះថ្ងៃទី...២១...ខែ...កញ្ញា...ឆ្នាំ ២០០៨

## តារាងសោហ៊ុយសេវាកម្មត្រួតពិនិត្យអនាម័យសត្វ

## និង ផលិតផលមានដើមកំណើតពីសត្វ

| ល.រ | រាយមុខទំនិញ | ឯកតា | ធ្វើចរាចរក្នុងផ្ទៃប្រទេស ថ្លៃឯកតា "រៀល" | ធ្វើចរាចរនាំចេញនាំចូល ថ្លៃឯកតា "រៀល" | ធ្វើចរាចរឆ្លងកាត់ប្រទេស ថ្លៃឯកតា "រៀល" |
|---|---|---|---|---|---|
| | ក. សត្វ | | | | |
| ១ | សត្វចតុប្បាទធំ( គោ ក្របី សេះ ដំរី ...) | ក្បាល | ២.០០០ | ៨.០០០ | ២.០០០ |
| ២ | សត្វចតុប្បាទតូច ( ជ្រូក ពពែ ចៀម ក្ដាន់...) | ក្បាល | ១.០០០ | ៤.០០០ | ២.០០០ |
| ៣ | សា្វ ទោច រួមទាំងអម្បូរសម្រាប់បង្កាត់ពូជទាំងនោះ | ក្បាល | ១.០០០ | ៤.០០០ | ២.០០០ |
| ៤ | បក្សី ( មាន់ ទា មាន់បារាំង ក្រួច...) | ក្បាល | ១០០ | ២០០ | ១០០ |
| ៥ | ឧរង្គសត្វ( សត្វល្មូន រួមបញ្ចូល អណ្ដើក ត្រកួត ក្រពើ...) | ក្បាល | | ៤.០០០ | ២.០០០ |
| ៦ | សត្វវង្គជាតិ( ក្ដាម បង្កង បង្គា ព្រោន...) | គ.ក្រ | | ១០០ | ៥០ |
| ៧ | សិប្បីជាតិ( ខ្យង គ្រុំ ងាវ មឹក...) | គ.ក្រ | | ១០០ | ៥០ |
| ៨ | មណ្ឌូកសត្វ( កង្កែប គីង្គក់...) | គ.ក្រ | | ១០០ | ៥០ |
| ៩ | ស៊ុតបក្សីសម្រាប់ភ្ញាស់ | គ្រាប់ | ៥ | ១០ | ៥ |
| ១០ | ទឹកកាមសត្វ | កំប៉ិត | ៥០០ | ១.០០០ | ៥០០ |
| ១១ | អំប្រីយ៉ុងសត្វ | ក្បាល | ២.០០០ | ៨.០០០ | ៤.០០០ |
| ១២ | ឃ្មុំ ដង្កូវនាង | គ.ក្រ | | ១០០ | ៥០ |
| ១៣ | មច្ឆជាតិ | គ.ក្រ | | ១០០ | ៥០ |

| | | | | | |
|---|---|---|---|---|---|
| | **ខ-សាច់ និង ផ្នែកបន្ទាប់បន្សំដទៃទៀតរបស់សត្វ ដែលអាចបរិភោគបាន** | | | | |
| ១ | សាច់សត្វទាំងមូល សាច់សត្វកាប់ជាដុំ សាច់ជាប់ឆ្អឹង សាច់កាប់ជាប់ឆ្អឹង សាច់សុទ្ធ(គ្មានជាប់ឆ្អឹង) និង ផ្នែកបន្ទាប់បន្សំដទៃទៀត ស្រស់ ឬ រក្សាទុកក្នុងទីត្រជាក់ ឬ បង្កក | គ.ក្រ | ៥០ | ២០០ | ១០០ |
| ២ | សាច់ងៀត សាច់ក្រក ម្សៅសាច់ ស្បែកជ្រូកក្រៀម | គ.ក្រ | ៥០ | ២០០ | ១០០ |
| ៣ | ខ្លាញ់សត្វគ្រប់ប្រភេទ មិនទាន់ចំរាញ់ នៅស្រស់ បង្កក ប្រឡាក់ ត្រាំទឹកអំបិល រាវ ឬ កក | គ.ក្រ | ២០ | ១០០ | ៥០ |
| ៤ | ទឹកដោះ ស្រស់ | លីត្រ | | ១០០ | ៥០ |
| ៥ | ស៊ុតស្រស់ ប្រៃ កំណរកូន | គ្រាប់ | ៥ | ១០០ | ៥០ |
| ៦ | ត្រីងៀត ឬ ត្រីឆ្អើរ | គ.ក្រ | | ២០០ | ១០០ |
| ៧ | ប្រហុក ផ្អក | គ.ក្រ | | ១០០ | ៥០ |
| ៨ | ទឹកឃ្មុំ | លីត្រ | | ២០០ | ១០០ |
| | **គ.ផលិតផលមានដើមកំណើតពីសត្វ សម្រាប់ប្រើក្នុងវិស័យផ្សេងៗ ដែលមិនអាចបរិភោគបាន** | | | | |
| ១ | ស្បែកស្រស់ប្រឡាក់អំបិល ឬ ស្ងួត | គ.ក្រ | ១០ | ១២០ | ១០០ |
| ២ | ភ្លុក ស្នែង ក្រចក ក្រញ៉ាំ ចំពុះ និង រោមដែលកាត់ចេញពីសត្វរស់ ឬ សត្វស្លាប់ | គ.ក្រ | | ៤០០ | ២០០ |
| ៣ | ផ្នែកបន្ទាប់បន្សំដទៃទៀតរបស់សត្វ ដូចជា ឈាមស្រស់ ម្សៅឈាម ឆ្អឹង ម្សៅឆ្អឹង | គ.ក្រ | ១០០ | ៤០០ | ២០០ |
| ៤ | ស្នូក ខ្លែងអណ្ដើក | គ.ក្រ | | ២០០ | ១០០ |
| ៥ | ត្រីហាលចំណីសត្វ ម្សៅត្រី | គ.ក្រ | | ២០០ | ១០០ |
| ៦ | ចំណីសត្វ | គ.ក្រ | | ១០០ | ៥០ |
| ៧ | ក្រមួនឃ្មុំ | គ.ក្រ | | ៤០០ | ២០០ |

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ [signature] រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ [signature]

គាត ឈន់ ចាន់ សារុន